ការបណ្ដុះរុក្ខជាតិ

ការសាក



ជំហានទី១ :
ត្រូវជ្រើសរើសរកមែកដែលមានអាយុចាស់ល្មម (មិនខ្ចីឬចាស់ពេក)។ កាត់អង្កន់បរិវេណក្រោមថ្នាំងប្រហែល ២-៣សម ហើយបកសម្បកចេញ ព្រមទាំងយកកាំបិតកោសសរសៃយកជ័រឲ្យអស់ ដោយកោសពីលើចុះមកក្រោម ព្រោះបើទុកវាធ្វើឲ្យដុះសាច់ឡើងវិញ មិនអាចដុះឫស។



ជំហានទី២:
យកដីដែលមានលាយជាមួយជីកំប៉ុស្ដ និងកំទេចស្រកីដូង អាចម៍រណារល្វយ ឬផេះ មកបិតរុំជុំវិញនៅត្រង់កន្លែងដែលបានយកសម្បកចេញ ដោយបិតពីលើមកក្រោម។ ជាការល្អ គេអាចលាបថ្នាំជំនួយដុះឫសសម្រាប់ជួយការចេញឫស ត្រង់កន្លែងដែលកាត់ផ្នែកខាងលើ។



ជំហានទី៣:
ប្រើស្រកីដូង រើសយកតែផ្នែកណាដែលមានប្រវែងស្មើគ្នា ដំទុកឲ្យល្អ និងត្រាំទឹកឲ្យជោក យកមកចងរុំព័ទ្ធពីលើដីនោះ ដោយចងនៅផ្នែកខាងលើ និងខាងក្រោម។ យើងអាចប្រើរបស់ផ្សេងទៀតដែលមានលក្ខណៈជប់ទឹកមកជំនួសស្រកីដូងក៏បានដែរ។ រួចស្រោចទឹកឲ្យជោក។



ជំហានទី៤:
យកស្បោង ឬថង់ប្លាស្ទិកមកចងរុំព័ទ្ធពីលើដីនោះដើម្បីរក្សាសំណើមឲ្យបានយូរ។

ការភ្ជាប់ភ្នែក



ជំហានទី១ :
ជ្រើសរើសផ្នែកនៃដើមទម្រដែលយើងចង់ភ្ជាប់ភ្នែកដើម្បីឲ្យមានលក្ខណៈសមស្រួន។ ឆូតសម្បកដើមទម្រជារាងអក្សរ "T" ឲ្យបានប្រវែង ២-៣ ស.ម ហើយគាស់បង្ហើបសម្បកសងខាងឲ្យហើបដើម្បីបំរុងយកភ្នែកពីដើមផលមកដាក់ខាងក្នុង។



ជំហានទី២ :
ជ្រើសរើសភ្នែកដែលកំពុងរីកចម្រើនពីមែកពូជល្អ(ផល) ចៀរយកភ្នែកឲ្យជាប់សាច់ឈើមកផង តែត្រូវយកសាច់ឈើចេញមុននឹងដាក់សៀតចូលក្នុងដើមទម្រដែលបានរៀបចំបម្រុងជាស្រេច។



ជំហានទី៣ :
យកភ្នែកដែលបានរៀបចំទុកដាក់សៀតចូលក្នុងដើមទម្រដែលបានរៀបបម្រុងជាស្រេចនោះ។



ជំហានទី៤ :
ក្រោយពីរៀបចំភ្នែកលើដើមទម្រស្រលបួលហើយ ចាំបាច់ត្រូវរុំប្លាស្ទិកការពារកុំឲ្យទឹកចូល ទុកចោលរយៈពេល ១៥-២៥ថ្ងៃ ត្រូវពិនិត្យមើលប្រសិនបើភ្នែកមានការលូតលាស់រីកចម្រើន មានន័យថា ការភ្ជាប់បានជោគជ័យហើយ ទើបយើងស្រាយយកស្បោងប្លាស្ទិកនោះចេញ។

ការតដើម



ជំហានទី១ :
ត្រៀមដើមដែលបានមកពីការបណ្ដុះគ្រាប់ពូជរុក្ខជាតិក្នុងស្រុកដែលមានឫសល្អ ធន់ទ្រាំជាមួយបរិយាកាសសត្វល្អិត ជម្ងឺដើម និងគួរមានអាយុប្រមាណពី ៤៥ថ្ងៃ ឬច្រើនជាងនេះ។



ជំហានទី២ :
កាត់ដើមដែលត្រូវយកមកតនោះឲ្យខ្ពស់ពីគល់ប្រមាណ ៤-៥សម ដោយប្រើកាំបិតមុត ដោយចិតពីគល់ឡើងទៅលើរបៀបបញ្ឆិតឲ្យមានភាពស្មើដើម្បីត្រៀមយកទៅដាក់ភ្ជាប់ជាមួយដើមពូជល្អ(ផល)។



ជំហានទី៣ :
បេះស្លឹកខ្លះចេញពីមែកដែលត្រូវតនិងប្រើកាំបិតចិតបញ្ឆិតឲ្យស៊ីគ្នាទៅនឹងស្នាមចិតនៃដើមដែលបានត្រៀមមកភ្ជាប់។



ជំហានទី៤ :
នាំយកដើមដែលបានត្រៀមមកភ្ជាប់មកបិតភ្ជាប់និងស្នាមចិតលើមែកឲ្យបានផ្អិបគ្នាល្អ ហើយរុំប្លាស្ទិកឲ្យណែនពីលើ ទុកចោលឲ្យបាន ២ខែ ទើបអាចកាត់បាន។

តើអ្នកចង់បានរុក្ខជាតិហូបផ្លែ
ដែលដុះលូតលាស់ល្អ
និងផ្តល់ផលច្រើនឬ?
ចូរចាប់ផ្តើមធ្វើការបណ្ដុះ!!!